# វេទិកាពលរដ្ឋ
# PEOPLE FORUM

សហរដ្ឋអាមេរិក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣

## សេចក្តីថ្លែងការណ៍

**វេទិកាពលរដ្ឋ** សូមថ្កោលទោសបុគ្គល **ផែង វណ្ណៈ** ដែលបានជេរប្រមាថ បែបអវិជ្ជាបំផុត រហូតដល់គំរាមសម្លាប់ ដោយពាក្យ*«ពុះក្បាលនឹងពូថៅ»* បែបចរិតឃាតកចេញមុខ លើលោក **តាំង សារ៉ាដា** ប្រធានការផ្សាយនៃសារព័ត៌មាន The Cambodia Daily ជាភាសាខ្មែរ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣។

សម្តីរបស់បុគ្គល **ផែង វណ្ណៈ** ដែលថា*«ពុះក្បាលនឹងពូថៅ ប្រសិនបើ* ***តាំង សារ៉ាដា*** *ហ៊ានមកជាន់ទឹកដីខ្មែរ»*បែបនេះ ជាការបង្ហាញថា របបដឹកនាំសង្គមកម្ពុជាសព្វថ្ងៃ ក្រោមអំណាចរបស់លោក **ហ៊ុន សែន** គឺស្រដៀងនឹងរបបប៉ុលពតខ្លាំងណាស់ បើបុគ្គល **ផែង វណ្ណៈ** មិនប្រឈមនឹងការផ្តន្ទាទោសទេ ពីព្រោះ មានតែរបបប៉ុលពតប៉ុណ្ណោះ ដែលពួកកាន់ការងាររបស់អង្គការគ្រប់លំដាប់ថ្នាក់ មានសិទ្ធិសម្លាប់ពលរដ្ឋគ្មានកំហុស តាមទំនើងចិត្ត និង បែបឥតសាសនា។ ឯណាទៅ សិទ្ធិរស់រានមានជីវិតជាមូលដ្ឋានរបស់ពលរដ្ឋខ្មែរ ដែលមន្ត្រីរដ្ឋាភិបាល**គណបក្សប្រជាជនកម្ពុជា** សូត្រឃោសនារាល់ថ្ងៃ និងអះអាងថា ត្រូវតែអនុវត្តឲ្យបាននោះ?

ដោយបានស្តាប់ប្រតិកម្មរបស់ប្រជាពលរដ្ឋទូទៅ យើងខ្ញុំដឹងច្បាស់ថា ពួកគាត់ទទួលយកមិនបានឡើយ ពេលឮសារសំឡេងដែលបង្ហាញចេតនាជាឃាតកររបស់បុគ្គល **ផែង វណ្ណៈ** ពីព្រោះ ការប៉ុនប៉ងសម្លាប់មនុស្ស និង ការសម្លាប់មនុស្ស ដោយចេតនាដោយបុគ្គលណាម្នាក់ ជាការបំពានធ្ងន់ធ្ងរលើរដ្ឋធម្មនុញ្ញ ក្រមព្រហ្មទណ្ឌ ច្បាប់សិទ្ធិមនុស្សសកល និង ច្បាប់សាសនាផង។

**វេទិកាពលរដ្ឋ** ដាស់តឿនលោក **ហ៊ុន សែន** ថា កាលណារដ្ឋាភិបាលចេះតែបណ្តោយឲ្យបុគ្គល ដែលមានចរិតជាឃាតកដូចឈ្មោះ **ផែង វណ្ណៈ** នេះ នៅតែបន្តបំពានច្បាប់ និង បង្កអសន្តិសុខដល់ពលរដ្ឋស្លូតត្រង់តទៅទៀត ទាំងមិនញញើតបន្តិចសោះ ដោយសកម្មភាពក្តី និងដោយពាក្យសម្តីគំរាមក្តី វានឹងរីករាលដាលទៅជាកំហឹងមហាជនចលាចលសង្គមនៅថ្ងៃណាមួយ។ ការចាត់ការបុគ្គល **ផែង វណ្ណៈ** តាមច្បាប់ជាធរមាន គឺជាជម្រើសត្រឹមត្រូវតែមួយគត់។

**អគ្គលេខាធិការវេទិកាពលរដ្ឋ**

Seng

**អ៊ាប សេង**

Address: 58 Poplar Street, Plains PA 18705, USA